**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 19-Sep-2012, 14:20
CMS/CFO: Uch Arun

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជសដ |
| ដាក់ទៅ | : | អង្គជំនុំជម្រះសាលាដំបូង |
| ថ្ងៃដាក់ | : | ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១១ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះសាលាដំបូង: **សាធារណៈ/Public**

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យឯកសារបណ្ដោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

**ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹង “សេចក្តីសន្និដ្ឋានរបស់ ខៀវ សំផន គាំទ្រសំណើរបស់លោក អៀង សារី ស្នើឲ្យអង្គជំនុំជម្រះសាលាដំបូង ធ្វើសំណើទៅកាន់ការិយាល័យសហចៅក្រមស៊ើបអង្កេត សុំការបញ្ជាក់អំពីអត្ថិភាពខ្សែអាត់សម្លេងនៃការស្តាប់ចម្លើយសាក្សី អឿន តាន កាលពីថ្ងៃទី៨ ខែតុលា ឆ្នាំ២០០៨”**

---

| អ្នកដាក់ឯកសារ: | អ្នកទទួលឯកសារ: | ចម្លងជូនជន: |
|---|---|---|
| សហព្រះរាជអាជ្ញា: | អង្គជំនុំជម្រះសាលាដំបូង: | ជាប់ចោទ: |
| លោកស្រី ជា លាង | ចៅក្រម និល ណុន, ប្រធាន | នួន ជា |
| លោក Andrew CAYLEY | ចៅក្រម Silvia CARTWRIGHT | អៀង សារី |
| | ចៅក្រម យ៉ា សុខន | ខៀវ សំផន |
| | ចៅក្រមJean-Marc LAVERGNE | |
| | ចៅក្រម យូ ឧត្តរា | ក្រុមមេធាវីការពារក្តី: |
| | | លោក សុន អរុណ |
| | សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី: | លោក Michiel PESTMAN |
| | | លោក Victor KOPPE |

| | |
|---|---|
| ពេជ អង្គ | លោក អាង ឧត្តម |
| Elisabeth SIMONNEAU FORT | លោក Michael G.KARNAVAS |
| | លោក គង់ សំអុន |
| | Anta GUISSE |
| | Arthur VERCKEN |
| | Jacques VERGES |

## I. សេចក្ដីផ្ដើម

១. កាលពីថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១២ មេធាវីការពារក្ដីឱ្យលោក ខៀវ សំផន ("មេធាវីការពារក្ដី") បានដាក់សំណើមួយ[1] សុំឱ្យអង្គជំនុំជម្រះសាលាដំបូង ចាត់វិធានការចំនួនបី (សំណើ)។ ទីមួយ មេធាវីការពារក្ដីសុំឱ្យអង្គជំនុំជម្រះសាលាដំបូងទទួលយកសំណើពីមុនមួយ ដែលធ្វើឡើងដោយមេធាវីការពារក្ដី អៀង សារី ដែលសុំឱ្យអង្គជំនុំជម្រះសាលាដំបូងស្វែងរកព័ត៌មានពី ការិយាល័យសហចៅក្រមស៊ើបអង្កេត ("កសចស") ពាក់ព័ន្ធនឹងការស្ដាប់ចម្លើយលោក អឿន តាន[2]។ ទីពីរ មេធាវីការពារក្ដីសុំឱ្យអង្គជំនុំជម្រះសាលាដំបូង "ធ្វើសំណើទៅកាន់ការិយាល័យ កសចស សុំឱ្យធ្វើការបំភ្លឺពាក់ព័ន្ធនឹងការស្ដាប់ចម្លើយលោក នង សុផង់"[3]។ ទីបី មេធាវីការពារ ក្ដីសុំឱ្យអង្គជំនុំជម្រះសាលាដំបូង "បន្តអនុវត្តនីតិវិធីដូចគ្នានេះនៅពេលអនាគតសម្រាប់ការស្ដាប់ ចម្លើយសាក្សីដទៃទៀត ដែលការកត់ត្រាកំណត់ហេតុរបស់ពួកគេ មានភាពមិនស៊ីសង្វាក់គ្នា ស្រដៀងគ្នានេះ"[4]។

២. សហព្រះរាជអាជ្ញាបានឆ្លើយតបទៅនឹងសំណើរបស់ អៀង សារី ពាក់ព័ន្ធនឹង អឿន តាន នៅក្នុងការដាក់ឯកសារមួយដែលបានជូនដំណឹងដល់ភាគីនានា កាលពីថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១២[5]។ ពីព្រោះការដាក់ឯកសារភ្លាមៗរបស់មេធាវីការពារក្ដីពុំបានផ្ដល់សំអាងបន្ថែមជាការគាំទ្រដល់ការដាក់ឯកសារពីមុនរបស់ អៀង សារី ឡើយ សហព្រះរាជអាជ្ញាស្នើដោយគោរពថា សូមឱ្យអង្គជំនុំជម្រះធ្វើការយោងទៅដល់ចម្លើយតបពីមុនរបស់សហព្រះរាជអាជ្ញាទាក់ទងនឹងផ្នែកត្រង់ នោះនៃសំណើរបស់មេធាវីការពារក្ដី។ សហព្រះរាជអាជ្ញានឹងធ្វើការលើកឡើងអំពីផ្នែកដែលនៅសេសសល់នានានៅក្នុងសំណើដូចខាងក្រោមនេះ។

៣. សហព្រះរាជអាជ្ញា សូមជូនសេចក្ដីសន្និដ្ឋានថា គេត្រូវបដិសេធសំណើនេះចោលទាំងស្រុង ពីព្រោះវាខកខានមិនបានធ្វើការបង្ហាញពីទឡ្ហីករណ៍តាមផ្លូវច្បាប់ណាមួយ ដែលនាំឱ្យអង្គជំនុំជម្រះសាលាដំបូង ធ្វើការពិនិត្យសារឡើងវិញពីដំណាក់កាលស៊ើបសួរនៅក្នុងសំណុំរឿង០០២ ដែលបានបញ្ចប់តាំងពីយូរមកហើយ និង ដែលបានប្ដឹងជំទាស់រួចមកហើយដែរ។

---

[1] **E224/2** មតិគាំទ្រសំណើរបស់លោក អៀង សារី ស្នើឱ្យអង្គជំនុំជម្រះសាលាដំបូង ធ្វើសំណើទៅកាន់ការិយាល័យសហចៅក្រមស៊ើបអង្កេត សុំការបញ្ជាក់អំពីអត្ថិភាពឯកសារសម្លេងនៃការស្ដាប់ចម្លើយសាក្សី អឿន តាន កាលពីថ្ងៃទី៨ ខែតុលា ឆ្នាំ២០០៨, ១០ កញ្ញា ២០១២, (បន្ទាប់ តទៅនេះហៅថា "សំណើ")។ បានជូនដំណឹងនៅថ្ងៃទី១០ កញ្ញា ២០១២។

[2] **E224/2** សំណើ, ត្រង់កថាខណ្ឌទី ៦។

[3] **E224/2** សំណើ, ត្រង់កថាខណ្ឌទី ៦។

[4] **E224/2** សំណើ, ត្រង់កថាខណ្ឌទី ៦។

[5] **E224/1** ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹង "សំណើរបស់លោក អៀង សារី ស្នើឱ្យអង្គជំនុំជម្រះសាលាដំបូង សុំការបញ្ជាក់ពី កសចស អំពីអត្ថិភាពនៃកំណត់ត្រា ឬការថតសម្លេងនានា ទាក់ទិននឹងការសួរសាក្សី អឿន តាន កាលពីថ្ងៃទី៨ ខែតុលា ឆ្នាំ២០០៨", ៧ កញ្ញា ២០១២។

៤. សហព្រះរាជអាជ្ញា ក៏បានកត់សម្គាល់ផងដែរថា ការដាក់ឯកសាររបស់មេធាវីការពារក្តី ខកខានមិនបានត្រូវទៅតាមសេចក្តីណែនាំអនុវត្តរបស់ អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធនឹង "ខ្លឹមសារនៃឯកសារ" ដែលត្រូវដាក់នៅចំពោះមុខអង្គជំនុំជម្រះ[6]។ បញ្ហាសំខាន់បំផុតគឺការខកខានមិនបានផ្តល់នូវ "សេចក្តីសង្ខេបអត្ថបទគតិយុត្តិដែលពាក់ព័ន្ធ រួមទាំងសម្រង់ប្រភពច្បាប់ដែលទាក់ទងនានា" ឬ "ការអះអាងលំអិតអំពីចំណុចមូលដ្ឋានច្បាប់"ណាមួយឡើយ[7]។ ផ្ទុយទៅវិញមេធាវីការពារក្តីគ្រាន់តែលើកឡើងទូទៗថា "រាល់អត្ថបទទាំងអស់ដែលធានាដល់ជនជាប់ចោទនូវសិទ្ធិទទួលបានការកាត់ក្តីប្រកបដោយយុត្តិធម៌"[8]។ មេធាវីការពារក្តីមិនបានយោងដល់យុត្តិសាស្ត្រ របស់អង្គជំនុំជម្រះណាមួយនៃ អវតក ឡើយ ឬ យុត្តិសាស្ត្ររបស់តុលាការដទៃៗទៀតឡើយ។ ដោយសារភាពសំខាន់នៃសំណើ ដែលបានលើកឡើងពីភាពមិនប្រក្រតីក្នុងការប្រមូលភស្តុតាងដោយចៅក្រមស៊ើបអង្កេត និង បានធ្វើការស្វែងរកចំណាត់ការពីអង្គជំនុំជម្រះសាលាដំបូងនោះ យ៉ាងហោចណាស់មេធាវីការពារក្តីគួរតែបញ្ជាក់ពីបញ្ញត្តិច្បាប់ពាក់ព័ន្ធ ដែលគេយកមកធ្វើជាមូលដ្ឋានសំណើនេះ។

៥. លើសពីនេះ ដោយមិនបានលើកឡើងពី "សេចក្តីសង្ខេបអង្គហេតុពាក់ព័ន្ធ" ដូចដែលសេចក្តីណែនាំអនុវត្តបានបង្គាប់នោះទេ តែមេធាវីការពារក្តីបែរជាគ្រាន់តែធ្វើការយោងទៅដល់កម្រងនៃទំព័រនានានៅក្នុងប្រតិចារឹក ហើយនិយាយបញ្ចៀងទៅរក "ភាពមិនស៊ីសង្វាក់គ្នារវាងពាក្យសំដីក្នុងប្រតិចារឹក និងកាលបរិច្ឆេទផ្លូវការនៃការស្តាប់ចម្លើយសាក្សី លោក នង សុផង់ ដែលលោកមេធាវីការពារក្តី Vercken បានលើកឡើងរួចហើយក្នុងពេលសវនាការ" ទៅវិញ[9]។ ដូច្នេះ ការដាក់ឯកសាររបស់មេធាវីការពារក្តីនេះ បណ្តាលឱ្យភាគីនានា និងអង្គជំនុំជម្រះសាលាដំបូង ធ្វើការវាយតម្លៃស្មានៗពីចរឹកលក្ខណៈពិតប្រាកដនៃការអះអាងនោះព្រមទាំងធ្វើការប៉ាន់ស្មានថាតើការអះអាងនោះត្រូវបានស្តែងចេញជាការគាំទ្រយ៉ាងដូចម្តេច។

## II. **អំណះអំណាង**

### ក. មេធាវីការពារក្តី ខកខានមិនបានបង្ហាញពីមូលដ្ឋាននៃការអះអាងរបស់ខ្លួនទាក់ទងនឹងសាក្សី នង សុផង់ ទេ

៦. សំណើនេះខកខានមិនបានចង្អុលភស្តុតាងដែលបង្ហាញអោយឃើញពីកំហុសណាមួយ ដែលធ្វើយុត្តិកម្មលើដំណោះស្រាយ ដែលខ្លួនបានស្នើសុំទាក់ទងនឹង នង សុផង់ ទេ។ដូចដែលសហព្រះរាជអាជ្ញាធ្លាប់បានពន្យល់រួច ហើយពាក់ព័ន្ធនឹងការអះអាងស្រដៀងគ្នា ដែលសំដៅទៅរកសាក្សីដទៃ

[6] សេចក្តីណែនាំអនុវត្ត អ.វ.ត.ក/០១/២០០៧/វិ.លើកទី៨, មាត្រា៥។

[7] សេចក្តីណែនាំអនុវត្ត អ.វ.ត.ក/០១/២០០៧/វិ.លើកទី៨, មាត្រា៥.១.គ-ឃ។

[8] **E224/2** សំណើ, ត្រង់កថាខណ្ឌទី៥។

[9] **E224/2** សំណើ, ត្រង់កថាខណ្ឌទី៣។

ទៀត[10]៖ ទី១)កំហុសនីតិវិធីណាមួយដែលបានកើតឡើងនៅដំណាក់កាលស៊ើបសួរត្រូវបានដោះស្រាយរួចហើយ, ទី២) ការបង្ហាញខ្លួនរបស់ នង សុផង់ នៅពេលសវនាការដើម្បីផ្តល់សក្ខីកម្ម ដែលមេធាវីការពារក្តីពេលនោះមានលទ្ធភាពពិនិត្យ និង បានធ្វើតេស្តពិនិត្យដេញដោលលើភ័ស្តុតាង ដែលជាសក្ខីកម្មរបស់ គាត់ ក្នុងគោលដៅការពារសិទ្ធិទទួលបាននូវការជំនុំជម្រះក្តីដោយយុត្តិធម៌ របស់ ខៀវ សំផន, និង ទី៣)កំណត់ហេតុលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយ នង សុផង់ បានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវ នូវការស្តាប់ចម្លើយ និង អនុលោមតាមវិធានរបស់អវតក។

### *i. កំហុសនីតិវិធីនៅដំណាក់កាលស៊ើបសួរដែលបានលើកឡើងចោទប្រកាន់ ត្រូវបានដោះស្រាយរួចហើយដោយដីកាដំណោះស្រាយ*

៧. សំណើនេះ គឺផ្អែកទាំងស្រុងនៅលើ កំហុសនីតិវិធីនៅដំណាក់កាលស៊ើបសួរដែលត្រូវបានចោទប្រកាន់ - ជាពិសេស ពីរបៀបដែលអ្នកស៊ើបអង្កេត កសចស បានប្រើក្នុងការស្តាប់ចម្លើយសាក្សី នង សុផង់។ យ៉ាងណាក៏ដោយ ដូចដែលអង្គជំនុំជម្រះនេះធ្លាប់បានធ្វើការសម្រេច ពីមុនរួចហើយថា“វិធានផ្ទៃក្នុងមិនបានចែងអំពីការពិនិត្យឡើងវិញដោយអង្គជំនុំជម្រះសាលាដំបូង អំពីភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរក្រោយពេលទទួលបានសំណុំរឿងក្តីនេះទេ”[11]។

៨. អនុលោមតាមវិធានទាំងនោះបណ្តឹងសុំមោឃភាពដោយមិនគោរពវិធានប្បញ្ញត្តិ អាចគ្រាន់តែលើកឡើងបាននៅក្នុងដំណាក់កាលមុនសវនាការប៉ុណ្ណោះ ហើយដោយអង្គជំនុំជម្រះនេះបានរកឃើញថា “[]ក្របខណ្ឌច្បាប់នៃ អវតក ទាក់ទងនឹងកិច្ចស៊ើបសួររបស់តុលាការដែលក្នុងនោះមានចែង គ្រប់គ្រាន់ អំពីនីតិវិធីក្នុងការថែការរក្សាការពារជនជាប់ចោទ ដែលក្នុងនោះរួមទាំងឱកាសដើម្បីលើកជូនសហចៅក្រមស៊ើបអង្កេត (សចស) ស្តីពីបញ្ហាណាមួយ នឹងបណ្តឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះ លើសេចក្តីសម្រេចដែលបានធ្វើឡើងដោយ សចស ប្រសិនជាយល់ឃើញថាចាំបាច់”[12]។ នៅក្នុងអម្លុងពេលនៃកិច្ចស៊ើបសួរ ជនជាប់ចោទដោយផ្អែកតាមវិធាន ៧៦នៃវិធានផ្ទៃក្នុង មានសិទ្ធិធ្វើពាក្យបណ្តឹង ដើម្បីសុំឱ្យធ្វើមោឃភាពនូវកំណត់ហេតុជាលាយលក្ខណ៍អក្សរ ឬកិច្ចស៊ើបសួរដទៃទៀត និងធ្វើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចដែលផ្ទុយ[13]។ នៅពេល

---

[10] *សូមមើល* **E224/1** ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹង “សំណើរបស់លោក អៀង សារី ស្នើឱ្យអង្គជំនុំជម្រះសាលាដំបូង សុំការបញ្ជាក់ពី កសចស អំពីអត្ថិភាពនៃកំណត់ត្រា ឬការថតសម្លេងនានាទាក់ទិននឹងការសួរសាក្សី អឿន តាន កាលពីថ្ងៃទី៨ ខែតុលា ឆ្នាំ២០០៨”, ៧ កញ្ញា ២០១២។ **E221/1**ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់ក្រុមមេធាវីការពារក្តី អៀង សារី ស្នើឱ្យស្តាប់ការបង្ហាញភ័ស្តុតាងពីអ្នកបកប្រែផ្ទាល់មាត់ ពាក់ព័ន្ធនឹងការស្តាប់ចម្លើយសាក្សី ភី ភួន លើកទីពីរ ធ្វើឡើងដោយ កសចស, ៤ កញ្ញា ២០១២។

[11] **E116** សេចក្តីសម្រេចលើសំណើរបស់ជនជាប់ចោទ នួន ជា ពាក់ព័ន្ធនឹងភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ (ឯកសារ E51/3, E82, E88 និង E92), ៩ កញ្ញា ២០១១, កថាខណ្ឌទី១៧ (បន្ទាប់តទៅនេះហៅថា “សេចក្តីសម្រេចលើភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ”)។

[12] ឯកសារលេខ **E116** សេចក្តីសម្រេចស្តីពីភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ, ត្រង់កថាខណ្ឌទី១៨។

[13] *សូមអានផងដែរ ឯកសារ* **E71/1** សេចក្តីសម្រេចលើញត្តិរបស់ អៀង សារី ដែលសុំឱ្យមានសវនាការដេញដោលលើការបំពេញកិច្ចស៊ើបសួរ, ចុះថ្ងៃទី៨ មេសា ២០១១,ទំព័រ២ (“[]ភាគីទាំងអស់មានលទ្ធភាពដាក់ពាក្យសុំដោយបញ្ជាក់មូលហេតុ ភាគី អំពីមោឃភាពផ្នែកណាមួយ

មានការជូនដំណឹងអំពីការបិទកិច្ចស៊ើបសួរ ភាគីនានាមានឱកាសថែមទៀតក្នុងការស្នើសុំឲ្យបំពេញកិច្ចស៊ើបសួរបន្ថែម និងធ្វើការច្រានចោលនូវពាក្យសុំណាមួយចំនួន ដែលជាកម្មវត្ថុនៃបណ្តឹងឧទ្ធរណ៍[14]។ វិធាន៧៦(៧)នៃវិធានផ្ទៃក្នុងបានចែងថា៖ “លើកលែងតែជាកម្មវត្ថុនៃបណ្តឹងឧទ្ធរណ៍ ដីកាដំណោះស្រាយត្រូវកែតម្រូវកំហុសនីតិវិធីក្នុងការស៊ើបសួរ។ គ្មានបញ្ហាណាមួយដែលពាក់ព័ន្ធ នឹងកំហុសនីតិវិធីបែបនេះ អាចត្រូវបានលើកឡើងនៅចំពោះមុខអង្គជំនុំជម្រះ ឬអង្គជំនុំជម្រះតុលាការកំពូលឡើយ”[15]។ ហេតុដូចនេះ វិធានរបស់ អវតក បានចែងយ៉ាងច្បាស់ក្រឡែតណាស់ថា ការតវ៉ាជំទាស់ណាមួយទាក់ទងនឹងនីតិវិធីនៃកិច្ចស៊ើបសួរ គឺត្រូវបានកម្រិតព្រំដែនត្រឹមតែដំណាក់កាលមុនសវនាការប៉ុណ្ណោះ។

៩. វិធានការដែលបានស្នើរបស់មេធាវីការពារក្តី អាចរំលោភទៅនឹងការបែងចែកដែលបានដំកល់ទុកទាំងនៅក្នុងវិធានផ្ទៃក្នុង និង ទាំងនៅក្នុងរចនាសម្ព័ន្ធទូទៅរបស់ អវតក រវាងដំណាក់កាលស៊ើបសួរ និង ដំណាក់កាលសវនាការ។ អង្គជំនុំជម្រះសាលាដំបូង “មិនមែនជាស្ថាប័នសម្រាប់ប្តឹងឧទ្ធរណ៍ ឬ ពិនិត្យឡើងវិញលើបណ្តឹងឧទ្ធរណ៍ទាក់ទងទៅនឹងសេចក្តីសម្រេចនានារបស់ [អង្គបុរេជំនុំជម្រះ]ឡើយ”[16]។ ហេតុដូចនេះ “[]ជាបញ្ហាទូទៅមួយ ការជំទាស់ទាក់ទងអំពីជំហាននៃនីតិវិធី ឬសេចក្តីសម្រេចនានាដែលបានធ្វើដោយ សចស និង ដោយអង្គបុរេជំនុំជម្រះនៅក្នុងដំណាក់កាលនៃកិច្ចស៊ើបសួរ ត្រូវតែបានលើកជូនទៅស្ថាប័នមានសមត្ថកិច្ចនានារបស់តុលាការ នៅមុនពេលដែលដីកាដំណោះស្រាយចូលជាស្ថាពរ”[17]។

១០. អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា ការលើកលែងចំពោះវិធាន៧៦(៧) អាចនឹងមាន “បើសិនជា ភាគីទាំងនេះអាចបង្ហាញឲ្យឃើញថាខ្លួនមិនមានឱកាសណាមួយដើម្បីរាវរកឲ្យឃើញនូវការធ្វើឲ្យខុសពីសភាពដើម distortion ដែលបានចោទប្រកាន់ នៅមុនពេលបើកសវនាការនោះឡើយ ឬបើសិនជាហាក់ដូចជាមានការចាំបាច់ក្នុងការរក្សាការពារនូវភាពត្រឹមត្រូវនៃដំណើរការជំនុំជម្រះក្តី”[18]។ គ្មានករណីលើកលែងណាមួយក្នុងចំណោមករណីលើកលែងទាំងនោះត្រូវបានយកមកអនុវត្តនៅទីនេះនោះឡើយ។ មេធាវីការពារក្តីមានឱកាសគ្រប់គ្រាន់ដើម្បីរាវរកបញ្ហាដែលពួកគេបានធ្វើការចោទប្រកាន់នៅក្នុងសំណើរបស់ពួកគេ ។ មេធាវីបានអះអាងថាពួកខ្លួនត្រូវបានប្រាប់

---

នៃដំណើរការនីតិវិធី ដែលពួកគេចាត់ទុកជាមោឃៈនៅក្នុងដំណើរការបំពេញកិច្ចស៊ើបសួរ ហើយថាសេចក្តីសម្រេចណាមួយលើពាក្យសុំនេះ គឺជាកម្មវត្ថុនៃបណ្តឹងឧទ្ធរណ៍នៅចំពោះមុខអង្គបុរេជំនុំជម្រះដោយអនុលោមតាមវិធានផ្ទៃក្នុង”)។

[14] វិធាន៦៦នៃវិធានផ្ទៃក្នុង។

[15] *សូមអានផងដែរ* ឯកសារលេខ **E71/1** សេចក្តីសម្រេចលើញត្តិរបស់ អៀង សារី ដែលសុំឲ្យមានសវនាការដេញដោលលើការបំពេញកិច្ចស៊ើបសួរ, ចុះថ្ងៃទី៨ មេសា ២០១១,ទំព័រ២។

[16] **E116** សេចក្តីសម្រេចស្តីពីភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ, ត្រង់កថាខណ្ឌទី១៨។

[17] ឯកសារលេខ **E116** សេចក្តីសម្រេចស្តីពីភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ, ត្រង់កថាខណ្ឌទី១៥ ។

[18] ឯកសារលេខ **E142/3** សេចក្តីសម្រេចលើសំណើរបស់ នួន ជា ដែលសុំឲ្យបំបេញកិច្ចស៊ើបសួរដោយអនុលោមតាមវិធាន៣៥ នៃវិធានផ្ទៃក្នុងពាក់ព័ន្ធនឹងភាពពុំត្រឹមត្រូវនៅក្នុងកំណត់ហេតុជាលាយលក្ខណ៍អក្សរនិងជាសម្លេងនៃការស្តាប់ចម្លើយសាក្សីរបស់ កសចស, ចុះថ្ងៃទី១៣ មីនា ២០១២, កថាខណ្ឌទី៧ (ដែលជាបន្តមកទៀតនៅក្នុងនេះហៅកាត់ថា “សេចក្តីសម្រេចស្តីពីការស្តាប់ចម្លើយសាក្សី”)។

ឲ្យដឹងអំពីសំនួរមួយដែលបានសួរទៅកាន់សាក្សី នង សុផង់ (Norng Sophong) ដែលមាននៅក្នុងខ្សែអាត់ថតសម្លេងនៃការស្តាប់ចម្លើយសាក្សីនោះ[19]។ ដូចដែលអង្គជំនុំជម្រះនេះបានធ្វើការកត់សម្គាល់កាលពីមុនមកថា៖

> *ទាំងខ្សែអាត់ថតសម្លេងទាំងកំណត់ត្រាត្រូវ....ដាក់បញ្ចូលនៅក្នុងសំណុំរឿងជាបន្តបន្ទាប់នៅក្នុងអំឡុងពេលបំពេញកិច្ចស៊ើបសួរ ហើយដូច្នេះភាគីអាចមានលទ្ធភាពពិនិត្យមើលឯកសារទាំងនេះបាន(ទាំងអ្នកចេះភាសាខ្មែរភាសាអង់គ្លេស និង/ឬ ភាសាបារាំង) ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ[20]។*

១១. ហេតុនេះ អង្គជំនុំជម្រះសាលាដំបូង បានច្រានចោលនូវសំណើមួយអនុលោមតាមវិធាន ៣៥ ដែលធ្វើឡើងដោយមេធាវីការពារក្តីរបស់ នួន ជា ដោយផ្អែកលើភាពមិនស៊ីសង្វាក់គ្នារវាងខ្សែអាត់ថតសម្លេង និងកំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយសាក្សីរបស់ សចស ដែលរកឃើញថា “[]នៅក្នុងអំឡុងដំណាក់កាលនៃកិច្ចស៊ើបសួរ ភាគីទាំងអស់បានមានសិទ្ធិក្នុងការចូលទៅពិនិត្យមើលសំណុំរឿង ដែលក្នុងនោះរួមទាំងខ្សែអាត់ថតសម្លេងផង”និងថា មេធាវីការពារក្តីបានខកខានក្នុងការបង្ហាញឲ្យឃើញថា មិនអាចមានលទ្ធភាពដើម្បីធ្វើការវាយតម្លៃអំពីអត្ថិភាពនៃភាពមិនប្រក្រតីនៅក្នុងកំណត់ហេតុជាលាយលក្ខណ៍អក្សរ “នៅមុនពេលបើកសវនាការ” បានទេ[21]។ ស្រដៀងគ្នានេះដែរនៅទីនេះ មេធាវីការពារក្តីអាចបានពិនិត្យមើលនូវខ្សែអាត់ថតសម្លេង និងកំណត់ហេតុលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយសាក្សី នង សុផង់។ ហេតុដូចនេះមិនមានការអនុគ្រោះលើកលែងស្របច្បាប់ណាមួយដោយសារការខកខានមិនបានរកឃើញ និង មិនបានលើកឡើងអំពីបញ្ហាទាក់ទងនឹងនីតិវិធីនៅមុនពេលបើកសវនាការ។

១២. លោកស្រីចៅក្រម Cartwright នៅក្នុងពេលថ្មីៗនេះបានបញ្ជាក់អះអាងឡើងវិញអំពីគោលការណ៍ទាំងនេះដល់ភាគីនានានៅក្នុងតុលាការ៖

> *ហេតុដូច្នេះ វិធានទូទៅនោះ គឺថាមានសច្ចធារណ៍គតិយុត្តិនិយាយអំពីសុចរិតភាពនៃការស៊ើបអង្កេតដែលថារាល់ការព្រួយបារម្ភពាក់ព័ន្ធទៅនឹងវិធីសាស្ត្រ ឬបញ្ហាណាមួយដែលកើតមានឡើងក្នុងអំឡុងពេលស៊ើបអង្កេតនេះ ត្រូវតែលើកឡើងក្នុងអំឡុងពេលស៊ើបអង្កេតនោះតែប៉ុណ្ណោះ។ ហើយឥឡូវនេះគឺនៅក្នុងពេលសវនាការ .....កិច្ចស៊ើបអង្កេតត្រូវបានចាត់ទុកថាជាចំណុចនៃការចាប់ផ្តើម ហើយអាចជំទាស់តវ៉ាបានតែនៅក្នុងករណីលើកលែងមួយចំនួនតែប៉ុណ្ណោះ។*

---

[19] ឯកសារលេខ **E1/122.1** ប្រតិចារិកនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី, ថ្ងៃទី ៥ ខែកញ្ញា ឆ្នាំ២០១២,ទំព័រ៦០។

[20] ឯកសារលេខ**E142/3** សេចក្តីសម្រេចស្តីពីការស្តាប់ចម្លើយសាក្សី, ត្រង់កថាខណ្ឌទី៦ និង ៨។

[21] ឯកសារលេខ**E142/3** សេចក្តីសម្រេចស្តីពីការស្តាប់ចម្លើយសាក្សី, ត្រង់កថាខណ្ឌទី៨។

> *ការជំទាស់តវ៉ាណាមួយរបៀបនេះមិនត្រូវពាក់ព័ន្ធទៅនឹងបញ្ហាបច្ចេកទេសនោះទេ ក៏ប៉ុន្តែត្រូវតែពាក់ព័ន្ធទៅនឹងខ្លឹមសារតែប៉ុណ្ណោះ។ ហើយចំពោះការលើកឡើងករណីលើកលែងមួយគឺថា[ភាគី]ត្រូវតែតម្រូវតាមលក្ខខណ្ឌអង្គជំនុំជម្រះសាលាដំបូងថា [ភាគីមួយមាន]មូលហេតុគ្រប់គ្រាន់ចំពោះការលើកឡើងពាក់ព័ន្ធទៅនឹងភាពគួរឲ្យជឿជាក់បាន នៅត្រង់ផ្នែកណាមួយនៃការស៊ើបអង្កេត។ ក្នុងការប្រើប្រាស់ពាក្យពេចន៍ច្បាប់ដ៏ល្បីល្បាញរបស់ប្រទេសខំមិនឡ [ភាគីមួយ]មិនអាចយកមកធ្វើជាអំណះអំណាងក្នុងករណីដែលមិនមានភស្តុតាងជាក់លាក់(fishing..expedition)នោះទេ។*
>
> *.....[ភាគី] ចាំបាច់ត្រូវតែបំពេញលក្ខខណ្ឌឲ្យបានគ្រប់គ្រាន់ជូនអង្គជំនុំជម្រះសាលាដំបូងថា មានមូលហេតុយ៉ាងត្រឹមត្រូវ ដើម្បីវិលត្រឡប់ចូលមកក្នុងការស៊ើបសួរវិញ ហើយធ្វើការស៊ើបសួរអំពីរឿងនេះ[22]។*

១៣. តាមការពិត ដូចដែលលោកស្រីចៅក្រម Cartwright បានធ្វើការសង្កេតថា ការប្រព្រឹត្តរបស់ កសចស ត្រូវមានសិទ្ធិ ក្នុងការទទួលបាននូវការសន្មតថាមានភាពប្រក្រតី ដែលមិនអាចឲ្យធ្វើការការជំទាស់តវ៉ាតាមរយៈញត្តិស្នើសុំនានា ដែលគ្រាន់តែ “វាយតម្លៃស្មានៗឬ គ្មានការចង្អុលបង្ហាញភស្តុតាង” ដែលដូចគ្នានឹងញត្តិបច្ចុប្បន្ននេះ[23]។

### *ii. សក្ខីកម្មរបស់សាក្សីរូបនេះនៅពេលសវនាការ នឹងបានជានឹងបានជាដំណោះស្រាយចំពោះវិការៈនីតិវិធីណាមួយនៅក្នុងការស្តាប់ចម្លើយសាក្សីរបស់ កសចសនិងការពារសិទ្ធិទទួលបានសវនាការដោយត្រឹមត្រូវយុត្តិធម៌របស់ជនជាប់ចោទ*

១៤. លើសពីនេះ ការលើកលែងមួយនៃវិធាន ៧៦(៧) គឺមិនចាំបាច់ទេនៅទីនេះដើម្បីការពារភាពត្រឹមត្រូវយុត្តិធម៌នៃកិច្ចដំណើរការនីតិវិធីសវនាការ។ ទោះជាមានវិការៈនីតិវិធីនៅក្នុងការស្តាប់ចម្លើយសាក្សីនង សុផង់ បានធ្វើឡើងតាមរបៀបណាមួយក្តី ក៏សាក្សីរូបនេះបានផ្តល់សក្ខីកម្មក្នុងតុលាការរួចហើយៗមេធាវីការពារក្តីក៏មានឱកាសដើម្បីសួរ ហើយថែមទាំងបានសួរដេញដោលរូបគាត់រួចហើយដែរទាំងនៅលើខ្លឹមសារនៃសក្ខីកម្មរបស់គាត់ និងទាំងលើនីតិវិធីដែលបានអនុវត្តនៅក្នុងការ

---

[22] ឯកសារលេខ **E1/123.1** ប្រតិចារិកនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី, ថ្ងៃទី ៦ ខែកញ្ញា ឆ្នាំ២០១២, ទំព័រ៤៣ ។ សូមអានផងដែរដូចគ្នានឹងខាងលើត្រង់ទំព័រពីទី៣៦-៣៧ (ដែលនៅក្នុងនោះលោកចៅក្រម ឡា វ៉េញ បានធ្វើការកត់សម្គាល់ថា “មានអង្គហេតុជាក់ស្តែងមួយចំនួន”, ដែលក្នុងនោះរួមមានអំពីថា“[]គឺការស៊ើបអង្កេតតុលាការដែលបានធ្វើឡើងមុនការជំនុំជម្រះនេះ គឺថាមានរយៈពេលរាប់ឆ្នាំមកហើយ។ ហើយនៅអំឡុងពេលនៃកិច្ចស៊ើបសួរ កិច្ចស៊ើបសួរត្រូវបានដាក់បញ្ចូលនៅក្នុងសំណុំរឿង. ក្រុមមេធាវីការពារក្តីក៏អាចចូលមើលសំណុំរឿងនេះបានដែរ។ ហើយជនជាប់ចោទក៏អាចពិនិត្យមើលបាន។ ...យើងមិនធ្វើការពិភាក្សាគ្នាស្តីពីកិច្ចស៊ើបសួរនោះទេមកដល់ត្រង់ចំណុចនេះនៃពេលវេលា...យើងមកទីនេះគឺដើម្បីធ្វើការសិក្សា និងពិនិត្យអំពីបញ្ហាខ្លឹមសារ។ បញ្ហាដែលទាក់ទងទៅនឹងកិច្ចស៊ើបសួរ ដែលមិនត្រូវឲ្យមានការតាំងសំនួរជាន់គ្នាឬច្រំដែលនោះឡើយ”)។

[23] ឯកសារលេខ **E142/3** សេចក្តីសម្រេចស្តីពីការស្តាប់ចម្លើយសាក្សី, ត្រង់កថាខណ្ឌទី១០។

ស្តាប់ចម្លើយរបស់គាត់ដោយ កសចស[24]។ ដូច្នេះ សិទ្ធិទទួលបានសវនាការដោយត្រឹមត្រូវរបស់ជនជាប់ចោទគឺទទួលបាននូវកិច្ចការពារយ៉ាងគ្រប់គ្រាន់ ទាក់ទងនឹងសក្ខីកម្មរបស់សាក្សីរូបនេះ។

១៥. ក្នុងការបដិសេធលើសំណើរបស់មេធាវីការពារក្តី នួន ជា អនុលោមតាមវិធាន ៣៥ ដែលបានផ្អែកភាពខុសគ្នារវាងអះអាងក្នុងកំណត់ហេតុស្តាប់ចម្លើយសាក្សី និងខ្សែអាត់សម្លេងនោះ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា មេធាវីការពារក្តី "ទោះក្នុងព្រឹត្តិការណ៍ណាក៏ដោយ នឹងត្រូវទទួលបានការការពារបន្ថែម តាមរយៈលទ្ធភាពក្នុងការសួរសាក្សីណាមួយនៅពេលសវនាការអំពីភាពខុសគ្នាដូចដែលគេបានអះអាងទាំងនោះ បើសិនជាមានភាពមិនស្របគ្នាដូចបានចោទប្រកាន់ទាំងនេះបង្ហាញឲ្យឃើញពីភាពពាក់ព័ន្ធទៅនឹងការវាយតម្លៃភ័ស្តុតាង ក៏ដូចជាមានទំនាក់ទំនងជាមួយភាពចាំបាច់ដើម្បីការពារភាពត្រឹមត្រូវយុត្តិធម៌នៃកិច្ចដំណើរការនីតិវិធីសវនាការ"[25]។ មេធាវីការពារក្តី ខៀវ សំផន និងក្រុមមេធាវីការពារក្តីដទៃទៀតបានត្រូវអនុញ្ញាតឲ្យសួរដេញដោល នង សុផង់ ហើយពេលនេះមិនអាចអះអាងដោយជឿជាក់ថា សិទ្ធិទទួលបានសវនាការដោយត្រឹមត្រូវរបស់ខ្លួនមិនទទួលបាននូវការការពារឲ្យបានគ្រប់គ្រាន់ទាក់ទងនឹងសក្ខីកម្មរបស់សាក្សីរូបនេះឡើយ។

១៦. គេគួរសង្កត់ធ្ងន់ផងដែរថា នង សុផង់ ពេលនេះបានផ្តល់សក្ខីកម្មសរុបជារួមចំនួនបីថ្ងៃកន្លះហើយនៅចំពោះអង្គជំនុំជម្រះសាលាដំបូង[26] អាស្រ័យហេតុនេះភាពខុសគ្នានៃនីតិវិធីដូចដែលបានអះអាងក្នុងការស្តាប់ចម្លើយសាក្សីរបស់ កសចស មានតិចតួចណាស់ ឬគ្មានវិបាកអ្វីធំដុំឡើយ។ ក្នុងរយៈពេលបីថ្ងៃកន្លះនៃការផ្តល់សក្ខីកម្មរបស់គាត់នៅក្នុងតុលាការ គឺជាភ័ស្តុតាងចំបងដែលកំពុងស្ថិតនៅចំពោះមុខអង្គជំនុំជម្រះនៅពេលនេះ។

### *ii. កំណត់ហេតុស្តាប់ចម្លើយសាក្សីរបស់ កសចស ឆ្លុះបញ្ចាំងយ៉ាងពិតប្រាកដនៃសក្ខីកម្មរបស់សាក្សីរូបនេះ និងបានអនុវត្តតាមវិធានផ្ទៃក្នុងសម្រាប់ អ.វ.ត.ក*

១៧. អង្គជំនុំជម្រះសាលាដំបូងធ្លាប់បានកត់សម្គាល់កាលពីលើកមុនថា "យោងតាមទម្លាប់នៃការអនុវត្តក្រោមច្បាប់កម្ពុជា ការស្តាប់ចម្លើយសាក្សីនៅចំពោះមុខ កសចស មិនមែនជាកំណត់ហេតុកត់ត្រាគ្រប់ពាក្យឥតល្អៀងទេ តែជារបាយការណ៍មួយដែលបានធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេតពីសេចក្តីថ្លែងការណ៍ដែលពាក់ព័ន្ធដែលបានធ្វើឡើងដោយសាក្សី ភាគីដើមបណ្តឹងរដ្ឋប្បវេណី ឬ

---

[24] **E1/122.1** ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធី, ៥ កញ្ញា ២០១២ ត្រង់ទំព័រ៦០-៦៥។

[25] **E142/3** សេចក្តីសម្រេចលើកំណត់ហេតុស្តាប់ចម្លើយសាក្សី ត្រង់កថាខណ្ឌទី១៤។ *សូមមើលផងដែរ* ឯកសារ **E116** សេចក្តីសម្រេចលើភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ, ត្រង់កថាខណ្ឌទី១៩។

[26] សូមមើល **E1/117.1** ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធី, ២៩ សីហា ២០១២។ **E1/120.1** ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធី, ៣ កញ្ញា ២០១២។ **E1/121.1** ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធី, ៤ កញ្ញា ២០១២។ **E1/122.1** ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធី, ៥ កញ្ញា ២០១២។ **E1/123.1** ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធី, ៦ កញ្ញា ២០១២។

ជនជាប់ចោទណាម្នាក់”[27]។ ដោយពុំគិតថាតើការពិភាក្សាបន្ថែមណាមួយនឹងត្រូវធ្វើឡើងដែរ ឬក៏អត់ទេ កំណត់ហេតុស្តាប់ចម្លើយសាក្សីជាលាយលក្ខណ៍អក្សរត្រូវបានសង្ខេបយ៉ាងត្រឹមត្រូវ និងទៀងត្រង់ពីចំណេះដឹងនិងសក្ខីកម្មរបស់សាក្សី។ សាក្សី នង ស៊ុផង់ បានបញ្ជាក់អះអាងពីភាពត្រឹមត្រូវរបស់កំណត់ហេតុនោះទាំងនៅពេលកំណត់ហេតុត្រូវបានធ្វើឡើង (តាមការចុះហត្ថលេខា និង ផ្តិតមេដៃនៅលើកំណត់ហេតុ)[28] និងពេលដែលគាត់បានមកបង្ហាញខ្លួនដើម្បីផ្តល់សក្ខីកម្មនៅក្នុងសាលសវនាការ[29]។

១៨. ថ្វីបើកំណត់ហេតុស្តាប់ចម្លើយសាក្សីមិនតម្រូវឲ្យធ្វើយ៉ាងដូច្នេះក្តី ក៏ការស្តាប់ចម្លើយសាក្សីរបស់ កសចស ភាគច្រើនត្រូវបានថតជាខ្សែអាត់សម្លេង ហើយខ្សែអាត់សម្លេងទាំងនោះក៏បានដាក់នៅក្នុងសំណុំរឿង និង អាចឲ្យមេធាវីការពារក្តី និងភាគីដទៃទៀតអាចពិនិត្យមើលបាន។ ដូចអង្គជំនុំជម្រះបានកត់សម្គាល់ ទម្លាប់នៃការអនុវត្តបែបនេះរបស់ កសចស គឺ “មិនស្របគ្នានឹងការអនុវត្តដែលមានការគិតទុកជាមុនណាមួយក្នុងការរារាំងដល់កិច្ចស៊ើបសួរឡើយ”[30]។

១៩. ជាការបន្ថែម កង្វះភាពជាក់លាក់ក្នុងឯកសាររបស់មេធាវីការពារក្តី ទាំងនៅលើចរិកលក្ខណៈខាងអង្គហេតុ និងអង្គច្បាប់ដើម្បីបំពេញទៅតាមបទដ្ឋានដែលបានចែងដោយអង្គជំនុំជម្រះ ដើម្បីឲ្យគេពិចារណាទទួលយកនូវ “ការចោទប្រកាន់អំពីភាពមិនស៊ីសង្វាក់គ្នារវាងខ្សែអាត់សម្លេង និងកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីជាលាយលក្ខណ៍អក្សរ វៀរលែងតែការចោទប្រកាន់ទាំងនោះបានបង្ហាញអត្តសញ្ញាណនៃភាពជាក់លាក់គ្រប់គ្រាន់ និងមានការជាប់ទាក់ទងគ្នាទៅនឹងភាពខុសគ្នាដូចដែលគេបានអះអាងនៅលើខ្លឹមសារ ដោយបង្ហាញឲ្យឃើញពីភាពពាក់ព័ន្ធយ៉ាងច្បាស់ទៅនឹងសវនាការ”[31]។ មេធាវីការពារក្តីមិនបានតាំងបង្ហាញឲ្យឃើញ ទោះបីក្នុងលក្ខណៈទូទៅ ឬជាក់លាក់ណាមួយក៏ដោយ អំពីថាតើមានបញ្ហាជាសារធាតុណាមួយនៅក្នុងកំណត់ហេតុស្តាប់ចម្លើយសាក្សីរបស់ កសចសឡើយ ហើយក៏មិនបានអនុវត្តតាមសេចក្តីណែនាំអំពីនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា “ភាគីណាមួយដែលលើកឡើងអំពីការតវ៉ាយ៉ាងដូច្នេះ ត្រូវបានមានបន្ទុកបន្ថែមមួយទៀតក្នុងការកំណត់អត្តសញ្ញាណនៃភាពមិនស៊ីសង្វាក់គ្នាតាមការអះអាងនោះឲ្យបានច្បាស់លាស់*ហើយផ្តល់ការជូនដំណឹងជាមុនឲ្យបានទាន់ពេលវេលាដល់អង្គជំនុំជម្រះ និងភាគីដទៃទៀត អំពីការចោទប្រកាន់ទាំងនេះ ហើយនិងឯកសារដែលពាក់ព័ន្ធនឹងការចោទប្រកាន់*[32]។ តាមពិត មេធាវីការពារក្តីមិនបានផ្តល់ការជូនដំណឹង ទោះជាទាន់ពេលឬមិនទាន់ពេល ដល់ភាគី ឬអង្គជំនុំជម្រះសាលាដំបូងឡើយថា ខ្លួនបានស្វែងរកការតវ៉ាចំពោះសាក្សីណាម្នាក់ ដោយផ្អែកលើភាពមិនស៊ីសង្វាក់គ្នារវាងកំណត់ហេតុពីមុនរបស់គាត់ និងខ្សែអាត់សម្លេងនៃបទសម្ភាសន៍របស់គាត់។ ផ្ទុយទៅវិញ ពួកគេ

---

[27] **E142/3** សេចក្តីសម្រេចលើកំណត់ហេតុស្តាប់ចម្លើយសាក្សី ត្រង់កថាខណ្ឌទី១១។

[28] **E3/64** កំណត់ហេតុស្តាប់ចម្លើយសាក្សី នង សុផង់, ១៨ កុម្ភៈ ២០០៩។

[29] **E1/117.1** ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធី, ២៩ សីហា ២០១២, ត្រង់ទំព័រទី៣៤។

[30] **E142/3** សេចក្តីសម្រេចលើកំណត់ហេតុស្តាប់ចម្លើយសាក្សី ត្រង់កថាខណ្ឌទី១៤។

[31] **E142/3** សេចក្តីសម្រេចលើកំណត់ហេតុស្តាប់ចម្លើយសាក្សី ត្រង់កថាខណ្ឌទី១២។

[32] **E142/3** សេចក្តីសម្រេចលើកំណត់ហេតុស្តាប់ចម្លើយសាក្សី ត្រង់កថាខណ្ឌទី១២ (សង្កត់ន័យត្រង់អក្សរទ្រេត)។

បានលើកពីការទាមទាររបស់ខ្លួនជាលើកដំបូង នៅក្នុងខណៈដែលពួកគាត់បានកំពុងសួរដេញដោល សាក្សី និង *បន្ទាប់ពី*សហព្រះរាជអាជ្ញានិងភាគីដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ចប់ការសួរដេញដោលរបស់ខ្លួនចំពោះសាក្សី។

### ខ. មេធាវីការពារក្តីមិនបានផ្តល់យុត្តិកម្មអំពីសកម្មភាពប្លែកពីធម្មតា ដែលខ្លួនស្វែងរកទាក់ទងនឹងសាក្សីអនាគតឡើយ

២០. មេធាវីការពារក្តីមិនបានបង្ហាញភ័ស្តុតាងចំពោះសំណើរបស់ខ្លួនទាក់ទងនឹង អឿន តាន, នង សុផង់ ឬសាក្សីដទៃផ្សេងទៀតឡើយ ដូច្នេះមិនអាចយកជាយុត្តិកម្មសម្រាប់វិធានការស្រដៀងគ្នាដែលបានស្នើឡើងសម្រាប់ប្រភេទសាក្សីអនាគត ដែលគេមិនស្គាល់អត្តសញ្ញាណក្នុងប្រភេទស្រដៀងគ្នានេះ “ដែលបទសម្ភាសន៍របស់ពួកគាត់ដែលបានធ្វើប្រតិចារឹក អាចមានភាពមិនស៊ីសង្វាក់គ្នាស្រដៀងគ្នានេះដែរ”[33]។

## III. សេចក្តីសន្និដ្ឋាន

២១. អាស្រ័យដោយមូលហេតុដូចបានថែងពីខាងលើ សហព្រះរាជអាជ្ញាសូមស្នើដល់អង្គជំនុំជម្រះច្រានចោលសំណើនេះទាំងស្រុង៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១២ | លោកស្រី ជា លាង សហព្រះរាជអាជ្ញា | ភ្នំពេញ | [signature] |
| | លោក Andrew CAYLEY សហព្រះរាជអាជ្ញា | | [signature] |

[33] **E224/2** សំណើសុំ, ត្រង់កថាខណ្ឌទី៦។